**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៣៨/២៥ **ក.ប**/ស.ជ.៣.ម.ក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេសសម្រាប់ឆ្នាំ២០២៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងជនបរទេសប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថាអនុលោមតាមច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា និងប្រកាសលេខ ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីបណ្ណការងារ និងសៀវភៅការងារជនបរទេស ក្រសួងសូមជម្រាបជូនដូចខាងក្រោម៖

១. ចំពោះជនបរទេស ដែលធ្លាប់មានបណ្ណការងារ និងសៀវភៅការងារ ត្រូវស្នើសុំពន្យារសុពលភាពបណ្ណការងារ និងសៀវភៅការងារជនបរទេស ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦**។

២. ចំពោះជនបរទេស ដែលទើបចូលមកធ្វើការងារ ឬប្រកបមុខរបរណាមួយនៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឱ្យបានមុនរយៈពេល ៩០ថ្ងៃ បន្ទាប់ពីចូលមកដល់ព្រះរាជាណាចក្រកម្ពុជា។

ការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស ត្រូវធ្វើឱ្យបានមុនកាលបរិច្ឆេទខាងលើនេះជាកំហិតតាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh។ ចំពោះការខកខានមិនបានអនុវត្តតាមកាលកំណត់ខាងលើ ក្រសួងនឹងចាត់វិធានការផាកពិន័យស្របតាមជំពូកទី១៦ នៃច្បាប់ស្តីពីការងារ និងប្រកាសអន្តរក្រសួងលេខ ៤៩៨ សហវ.ប្រក.អទច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ និងជនបរទេសទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ៣កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ១២ ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- គ្រប់សមាគមនិយោជក
- ឯកសារ កាលប្បវត្តិ